ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីប្រព័ន្ធសៀ្វងបម្រុងកម្ពុជា | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ | ៤ |
| ៤- | សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ | ៦ |
| ៥- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន | ៨ |
| ៦- | សេចក្តីព្រាងអនុក្រឹត្យស្តីពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា | ៩ |
| ៧- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

# សេចក្តីព្រាងគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ

កាលពីថ្ងៃទី២២និងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អាំង គុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

រដ្ឋបាលសាធារណៈកម្ពុជាបានក្លាយជារដ្ឋបាលឯកភាពជាតិតែមួយនាដើមឆ្នាំ១៩៩៩ បន្ទាប់ពីការធ្វើសមាហរកម្មគ្រប់ភាគីនយោបាយខ្មែរទាំងអស់ដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ ទន្ទឹមនឹងនេះ មូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់គ្រប់គ្រងរដ្ឋបាលសាធារណៈត្រូវបានកសាងឡើងដូចជា ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ ចំនួន ២១ក្របខ័ណ្ឌ ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល ការកសាងមូលដ្ឋានទិន្នន័យមន្ត្រីរាជការ ការរៀបចំការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំប្រព័ន្ធចំណាត់ថ្នាក់ថ្មី ការធ្វើសមាហរណកម្មបញ្ចូលទៅក្នុងប្រព័ន្ធចំណាត់ថ្នាក់ថ្មីនេះ ការរៀបចំប្រព័ន្ធលាភការថ្មី ការដាក់ឲ្យអនុវត្តនូវតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំយុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈ ព្រមទាំងការពង្រឹងយន្តការគ្រប់គ្រងនិងការត្រួតពិនិត្យក្របខ័ណ្ឌឲ្យកាន់តែមានប្រសិទ្ធភាព ដូចជា ការជ្រើសរើសចូលក្របខ័ណ្ឌ ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌ ការឡើងថ្នាក់ ឋានន្តរសក្តិ និងការដាក់ឲ្យចូលនិវត្តន៍ ។ល។



នៅក្នុងបរិបទនៃសកលភាវូបនីយកម្មនិងការប្រកួតប្រជែងលើឆាកអន្តរជាតិ រាជរដ្ឋាភិបាលបានចាត់ទុកការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពនានារបស់រាជរដ្ឋាភិបាល។ ការពង្រឹងនឹងការកែលម្អដំណើរការនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ដើម្បីប្រែក្លាយធនធានមនុស្សនៅ

ក្នុងវិស័យសាធារណៈឲ្យកាន់តែមានសមត្ថភាព មានវិជ្ជាជីវៈច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការបំពេញការងារ។

គោលនយោបាយធនធានមនុស្សរៀបចំឡើង ដើម្បីជួយដល់ក្រសួង ស្ថាប័នក្នុងការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស និងជួយធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពការងារ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពល្អ អាចជឿទុកចិត្តបាន និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ។ គោលនយោបាយធនធានមនុស្ស ក៏នឹងជួយដល់អ្នកដែលមានតួនាទីគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ឲ្យយល់កាន់តែច្បាស់ពីរបៀបរបបការងារ ដែនសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ការចាត់ចែងនឹងការទទួលខុសត្រូវការងារ ការតាមដាននិងការវាយតម្លៃប្រសិទ្ធភាពការងាររបស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនផងដែរ[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។

# កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

## សេចក្តីព្រាងអនុក្រឹត្យស្តីពី ប្រព័ន្ធស្បៀងបម្រុងកម្ពុជា

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទទួលបានអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីប្រព័ន្ធស្បៀងបម្រុងកម្ពុជា ក្នុងគោលបំណងគ្រប់គ្រងប្រព័ន្ធព័ត៌មានស្បៀងនិងគ្រាប់ពូជបម្រុង ស្ថានភាពសន្និធិស្បៀង និងគ្រាប់ពូជ និងធនធានហិរញ្ញវត្ថុរបស់ប្រព័ន្ធស្បៀងបម្រុងកម្ពុជា បង្កើតគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា និងមានវិសាលភាពគ្របដណ្តប់លើប្រជាពលរដ្ឋនិងប្រជាកសិកររងគ្រោះដោយសារគ្រោះមហន្តរាយ ឬគ្រោះអាសន្ននានា ដែលត្រូវការជាបន្ទាន់នូវស្បៀងនិង/ឬគ្រាប់ពូជចាំបាច់សម្រាប់ស្តារឡើងវិញនូវផ្ទៃដីដាំដំណាំស្រូវ បន្លែ និងដំណាំរួមផ្សំផ្សេងៗ។

សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកតាមរយៈក្រុមបច្ចេកទេសនៃគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ កិច្ចប្រជុំនៃក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ហើយចុងក្រោយឆ្លងកិច្ចប្រជុំនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលចំណងជើងអនុក្រឹត្យទៅជា អនុក្រឹត្យស្តីពីប្រព័ន្ធស្បៀងនិងគ្រាប់ពូជបម្រុងកម្ពុជា និងមានការកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ

កាលពីថ្ងៃទី៦និងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ប្រាក់ សិទ្ធិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការពារជាតិ ។



ក្រសួងការពារជាតិបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ ដើម្បីឆ្លើយតបនឹងតម្រូវការបន្ថែមទៀតក្នុងការលើកកម្ពស់គុណភាពបណ្តុះបណ្តាលកម្រិតគ្រឹះស្ថានឧត្តមសិក្សាក្នុងវិស័យការពារជាតិសម្រាប់អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សានានាទាំងក្នុងប្រទេស ទាំងក្រៅប្រទេស។

កន្លងមករាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន៦គឺ១-អនុក្រឹត្យលេខ៥៥ អនក្រ.បក ស្តីពីការតម្លើងសាលានាយទាហានត្បាតពងទៅជាសាលានាយទាហានសកម្មមានកម្រិតស្មើគ្រឹះស្ថានឧត្តមសិក្សា ២-អនុក្រឹត្យលេខ៦១ អនក្រ.បក ស្តីពីការតម្លើងឋានៈសាលាពេទ្យកងយោធពលខេមរភូមិន្ទ ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ៣-អនុក្រឹត្យលេខ១៣២ អនក្រ.បកស្តីពីការប្តូរឈ្មោះ និងដំឡើងឋានៈវិទ្យាស្ថានយោធាកម្ពុជាទៅជាសាកលវិទ្យាល័យការពារជាតិដែលក្នុងនោះមាន៥មហាវិទ្យាល័យគឺ មហាវិទ្យាល័យការពារជាតិ មហាវិទ្យាល័យបញ្ជាការសេនាធិការ មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមនិងភាសា មហាវិទ្យាល័យអប់រំចិត្តសាស្ត្រនិងស្រាវជ្រាវវិទ្យាសាស្ត្រយោធា និងមហាវិទ្យាល័យព័ត៌មានវិទ្យានិងភស្តុភារ-ហិរញ្ញវត្ថុយោធា ៤-អនុក្រឹត្យលេខ៣៨ អនក្រ.បក ស្តីពីការប្រែប្រួលសាលានាយទាហានចម្រុះទៅជាវិទ្យាស្ថានទ័ពជើងគោក

៥-អនុក្រឹត្យលេខ១២ អនក្រ.បក ស្តីពីការប្រែក្លាយសាលាជំនាញឯកទេសចម្រុះទៅជាវិទ្យាស្ថានបច្ចេកទេសយោធាតេជោ **ហ៊ុន សែន** និង៦-អនុក្រឹត្យលេខ២២២ អនក្រ.បក ស្តីពីការរៀបចំយន្តការកម្រិតថ្នាក់ និងកំណត់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ និងលើកកម្ពស់ជីវភាពយោធាចារ្យដើម្បីជំរុញគុណភាពនៃការហ្វឹកហ្វឺន បណ្តុះបណ្តាលធនធានមនុស្ស(១)។







អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។

## សេចក្តីព្រាងច្បាប់ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **នាល់ ណៃអ៊ីម** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌( ECOSOCC ) និង ឯកឧត្តម **សុត គឹមសាន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ ក៏ដូចជាសេចក្តីព្រាងច្បាប់មុន ៗដែរ គឺពិតជាត្រូវបានសម្រេចចេញជាលទ្ធផល ក្រោមការដឹកនាំចង្អុលបង្ហាញ និងគាំទ្រជាប្រចាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងឋានៈជាអគ្គមេបញ្ជាការតែមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ជាការអភិវឌ្ឍហិរញ្ញវត្ថុនិងសេដ្ឋកិច្ចទូទៅ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី បានរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយគោរពបានទាំងស្រុង ទាំងកាលវសាន ទាំងខ្លឹមសារនៃមាត្រា៣៩ ដែលតម្រូវដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ បន្ទាប់ពីធ្វើការបូកសរុប និងធ្វើតុល្យភាពទាំងថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិរួចមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការប្រជុំវេចខ្ចប់ជាចុងក្រោយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ។



សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាបានងើបចេញពីវិបត្តិសេដ្ឋកិច្ចសកលយ៉ាងឆាប់រហ័យ ហើយបាននឹងកំពុងបង្ហាញនូវភាពមាំមួនឆ្ពោះទៅរកគោលដៅគោលនយោបាយកំណើនប្រចាំឆ្នាំ៧%របស់រាជរដ្ឋាភិបាលកម្ពុជាទោះស្ថិតនៅក្នុងលក្ខណៈផុយស្រួយនិងហានិភ័យខ្ពស់នៅឡើយក៏ដោយ។

# កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

កន្លងទៅរាជរដ្ឋាភិបាលមិនត្រឹមតែរក្សាបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងរក្សាបាននូវអធិបតេយ្យភាព បូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាពសង្គម នៅក្នុងពេល និងក្រោយពេលមានវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក ព្រមទាំងវិបត្តិព្រំដែនកម្ពុជា-ថៃ និងគ្រោះទឹកជំនន់ប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវកេរ្តិ៍ឈ្មោះដែលកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី១៥ លើពិភពលោកក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងស្ថិតក្នុងចំណាត់ថ្នាក់ទី១ នៅអាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។



សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣នេះ គឺជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុត ដើម្បីអនុញ្ញាតឲ្យរាជរដ្ឋាភិបាលបន្តអនុវត្តបញ្ចប់ “ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ “ និង “ យុទ្ធសាស្ត្រចតុកោណជំហានទី២ “ សំដៅឈានទៅសម្រេចឲ្យបាននូវ “ របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច “ នៃ “ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ “(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នះ ហើយបានសម្រេចកែសម្រួលបន្តិចបន្តួចលើពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី
# ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

កាលពីថ្ងៃទី១៩ និងថ្ងៃទី២១ ខែកញ្ញា និងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទីនិងម៉ោង ១៥:០០ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អ៊ួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុត គឹមសាន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើត **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



អនុវត្តតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំ សំដៅឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងអប់រំ យុវជន និងកីឡា បានកសាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ដើម្បីបំពេញបន្ថែមដល់ការអនុវត្តច្បាប់ស្តីពីអប់រំឲ្យមានប្រសិទ្ធភាព។

ឆ្លើយតបទៅនឹងការចង្អុលបង្ហាញរបស់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាដែលតម្រូវឲ្យបង្កើតយន្តការផ្សេងៗ ក្នុងគោលបំណងអនុវត្តគោលនយោបាយនេះឲ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងចំនួនពីរគឺ: សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ ហើយបានបន្តពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រហូតដល់ចប់។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

# សេចក្តីព្រាងអនុក្រឹត្យស្តីពី
# ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **លី គឹមសុខ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ខៀវ សារ៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។

ក្រសួងផែនការបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងរៀបចំរចនាសម្ព័ន្ធថ្នាក់ជាតិ សម្រាប់ការងារជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ ខាងមុខនេះ។ កន្លងមកក្រសួងផែនការធ្លាប់បានធ្វើជំរឿនប្រជាសាស្ត្រចំនួនពីរលើក គឺនៅឆ្នាំ១៩៩៨ និងនៅឆ្នាំ២០០៨ និងជំរឿនសហគ្រាសមួយលើក នៅឆ្នាំ២០១១ ហើយជំរឿនទាំងអស់នេះសុទ្ធតែត្រូវបានរៀបចំជាអនុក្រឹត្យស្តីពីជំរឿនផងដែរ។ ជំរឿនកសិកម្មជាជំរឿនមួយនៃជំរឿនទាំងបីដែលមានចែងនៅក្នុងច្បាប់ស្តីពីស្ថិតិ ដែលត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយមានការសហការពីនាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យោងតាមច្បាប់ស្តីពីស្ថិតិឆ្នាំ២០០៥ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងឆ្នាំ២០១០ បានតម្រូវឲ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើជំរឿនកសិកម្ម យ៉ាងតិចមួយដងក្នុងរយៈពេល១០ឆ្នាំ ហើយជំរឿនកសិកម្មឆ្នាំ២០១៣ ជាជំរឿនលើកទី១នៅព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងនេះ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំចេញអង្ករក្នុងបរិមាណធំ ហើយនិងនយោបាយដីធ្លីបច្ចុប្បន្ន តម្រូវឲ្យធ្វើជំរឿនកសិកម្មនាពេលខាងមុខ គឺជាកត្តាសំខាន់មិនអាចខ្វះបាន ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម(២០០៩-២០១៣) និងផែនការមេស្ថិតិបច្ចុប្បន្នកម្ម(២០០៨-២០១៥)(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១២ ម៉ោង ០៩ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីគម្រោងសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០១/១១/១២ ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្ទេរតំណែងប្រធានគណៈមេធាវីថ្មី សម្រាប់អាណត្តិទី៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ៣ | ០២/១១/១២ ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីសេសានក្រោម២ និងការវិនិយោគគម្រោងនេះ។<br>២-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ០៣/១១/១២ ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃ និងត្រួតពិនិត្យការងារជួសជុលកែលម្អផ្លូវអមសងខាងកំណាត់ផ្លូវ T1 នៅបុរីវប្បធម៌ និងទេសចរណ៍អង្គរខេត្តសៀមរាប។ |
| ៥ | ០៣/១១/១២ ម៉ោង ១០ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃ និងត្រួតពិនិត្យការងារសាងសង់ សំណង់គ្រប់គ្រងទឹកក្នុងតំបន់សៀមរាប-អង្គរ នៅខេត្តសៀមរាប។ |
| ៦ | ០៣/១១/១២ ម៉ោង ១៣ : ០០ នាទី | ចូលរួមត្រួតពិនិត្យការងារសាងសង់ និងគំនូរនៅសារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) ក្នុងខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នៅការដ្ឋានសាងសង់សារមន្ទីរសព្វទស្សន៍ ខេត្តសៀមរាប។ |
| ៧ | ០៤/១១/១២ ម៉ោង ១៥ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកួតកីឡាប្រដាល់ក្បាច់គុនបុរាណខ្មែរ និងមួយថៃវីរយុទ្ធ (Muay Thai Warriors) ដណ្តើមពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ ណាហ្គាវើល។ |
| ៨ | ០៦/១១/១២ ម៉ោង ០៩ : ៣០ នាទី | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយ ឯកឧត្តម **តិច សំណាង** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ០៦/១១/១២ ម៉ោង ១៥ : ៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ IATA (International Air Transport Association) និងលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១០ | ០៨/១១/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររងជំនាន់ទី១ ថ្នាក់បរិញ្ញាបត្រជំនាន់ទី១ ទី២ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១ ជូនដល់និស្សិតសាកលវិទ្យាល័យចេនឡា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១១ | ០៩/១១/១២<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីដុតទៀនជ័យ ខួបអនុស្សាវរីយ៍លើកទី ៥៩ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមអធិបតីភាព សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។ |
| ១២ | ១១/១១/១២<br>ម៉ោង ១៦ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពន្លត់ទៀនជ័យ ខួបអនុស្សាវរីយ៍លើកទី ៥៩ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមអធិបតីភាព សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។ |
| ១៣ | ១៣/១១/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធី នៃការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងការកែប្រែ ឈ្មោះផ្លូវ និងលេខផ្លូវ។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៤/១១/១២<br>ម៉ោង ០៩ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តមអនុប្រធាន និងឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ ឯកឧត្តមប្រធាន(ECOSOCC)នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៤/១១/១២<br>ម៉ោង ១៥ : ៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ហុង ថា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៤/១១/១២<br>ម៉ោង ១៧ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **តាំង គុងហ៊ាង** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ១៨/១១/១២<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ (The Opening Ceremony of the 21st ASEAN Summit and Related Summits) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | ២០/១១/១២<br>ម៉ោង ១៥ : ៤៥នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទកិច្ចប្រជុំកំពូលអាស៊ានលើកទី ២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ (The Closing Ceremony of the 21st ASEAN Summit and Related Summits) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៩ | ២១/១១/១២<br>ម៉ោង ១៦ : ០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់ ដើម្បីពិភាក្សាលើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យា នៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៣/១១/១២<br>ម៉ោង ១៥ : ០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់អគារទីស្នាក់ការអាជ្ញាធរអប្សរា ដើម្បីត្រួតពិនិត្យវាយតម្លៃ និងប្រគល់-ទទួលក្រោយពេលបញ្ចប់សុពលភាពអគារទីស្នាក់ការអាជ្ញាធរអប្សរា ក្នុងខេត្តសៀមរាប នៅទីស្នាក់ការអាជ្ញាធរអប្សរា ខេត្តសៀមរាប។ |
| ២១ | ២៤-២៥/១១/១២<br>ម៉ោង ០៩ : ០០នាទី | ដឹកនាំគណៈកម្មការបច្ចេកទេស ចុះបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យគម្រោងសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅខេត្តសៀមរាប។ |
| ២២ | ២៦/១១/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានស្ថាបនាស្ពានអាកាស ស្ទឹងមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅស្ពានស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ |
| ២៣ | ២៦/១១/១២<br>ម៉ោង ១៦ : ៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបិទវេទិកាបណ្ឌិតសភាលើកទី ៦ ស្តីពី "៥ឆ្នាំក្រោយការចុះហត្ថលេខាលើធម្មនុញ្ញអាស៊ាន៖ សមិទ្ធិផល និងបញ្ហាប្រឈមនៃដំណើរការសមាហរណកម្មអាស៊ាន" នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់។ |
| ២៤ | ២៩/១១/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គលើកទី ១២ នៃវេទិកាទេសចរណ៍អន្តរតំបន់អាស៊ីបូព៌ា (East Asia Inter-Regional Tourism Forum-EATOF) ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ អង្គរអេរ៉ា ខេត្តសៀមរាប។ |
| ២៥ | ៣០/១១/១២<br>ម៉ោង ១៥ : ៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១២<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្ទេរតំណែងប្រធានគណៈមេធាវីថ្មី សម្រាប់អាណត្តិទី ៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ២ | ០៤/១១/១២<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកួតកីឡាប្រដាល់ក្បាច់គុនបុរាណខ្មែរ និងមួយថៃវ៉ារីយែរ (Muay Thai Warriors) ដណ្តើមពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ ណាហ្គាវើល។ |
| ៣ | ២១/១១/១២<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមក្នុងពិធីរំលឹកខួបឆ្នាំទី២០ នៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Haruhiko Kuroda ប្រធាន ADB នៅវិមានសន្តិភាព។ |
| ៤ | ២៦/១១/១២<br>ម៉ោង ១៦ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវេទិកាបណ្ឌិតសភាលើកទី ៦ ស្តីពី "៥ឆ្នាំក្រោយការចុះហត្ថលេខាលើធម្មនុញ្ញអាស៊ាន៖ សមិទ្ធិផល និងបញ្ហាប្រឈមនៃដំណើរការសមាហរណកម្មអាស៊ាន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់។ |
| ៥ | ២៩/១១/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គលើកទី ១២ នៃវេទិកាទេសចរណ៍អន្តរតំបន់អាស៊ីបូព៌ា (East Asia Inter-Regional Tourism Forum-EATOF) ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ អង្គរអេរ៉ា ខេត្តសៀមរាប។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២

## ឯកឧត្តម ឌុយ ចៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១២ ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្ទេរតំណែងប្រធានគណៈមេធាវីថ្មី សម្រាប់អាណត្តិទី ៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ២ | ០៤/១១/១២ ម៉ោង ១៥ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកួតកីឡាប្រដាល់ក្បាច់គុនបុរាណខ្មែរ និងមួយថៃវីរៈយរ (Muay Thai Warriors) ដណ្តើមពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ ណាហ្គាវើល។ |
| ៣ | ២៦/១១/១២ ម៉ោង ១៦ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវេទិកាបណ្ឌិតសភាលើកទី ៦ ស្តីពី "៥ឆ្នាំក្រោយការចុះហត្ថលេខាលើធម្មនុញ្ញអាស៊ាន៖ សមិទ្ធិផល និងបញ្ហាប្រឈមនៃដំណើរការសមាហរណកម្មអាស៊ាន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់។ |
| ៤ | ២៩/១១/១២ ម៉ោង ០៩ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គលើកទី ១២ នៃវេទិកាទេសចរណ៍អន្តរតំបន់អាស៊ីបូព៌ា (East Asia Inter-Regional Tourism Forum-EATOF) ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ អង្គរអេរ៉ា ខេត្តសៀមរាប។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២

## ឯកឧត្តម ថាន់ គិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១១/១២<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្ទេរតំណែងប្រធានគណៈមេធាវីថ្មី សម្រាប់អាណត្តិទី ៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ២ | ០៤/១១/១២<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកួតកីឡាប្រដាល់ក្បាច់គុនបុរាណខ្មែរ និងមួយថៃវ៉ារីយ័រ (Muay Thai Warriors) ដណ្តើមពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ ណាហ្គាវើល។ |
| ៣ | ២១/១១/១២<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមក្នុងពិធីរំលឹកខួបឆ្នាំទី២០ នៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Haruhiko Kuroda ប្រធាន ADB នៅវិមានសន្តិភាព។ |
| ៤ | ២៦/១១/១២<br>ម៉ោង ១៦ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវេទិកាបណ្ឌិតសភាលើកទី ៦ ស្តីពី “៥ឆ្នាំក្រោយការចុះហត្ថលេខាលើធម្មនុញ្ញអាស៊ាន៖ សមិទ្ធិផល និងបញ្ហាប្រឈមនៃដំណើរការសមាហរណកម្មអាស៊ាន” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់។ |
| ៥ | ២៩/១១/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គលើកទី ១២ នៃវេទិកាទេសចរណ៍អន្តរតំបន់អាស៊ីបូព៌ា (East Asia Inter-Regional Tourism Forum-EATOF) ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ អង្គរអេរ៉ា ខេត្តសៀមរាប។ |

# ព្រឹត្តិបត្រព័ត៌មាន


| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ខ៉ាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្តដា | មន្ត្រី ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in